**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ៧២៣
ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣
សាលក្រមលេខៈ០៤៤/២៣ "ធ"
ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្តាល**

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៣ ខែវិច្ឆិកា ២០២៣ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ លើសំណុំរឿងរដ្ឋប្បវេណីលេខៈ៧២៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**ដែលមានភាគីដើមចោទៈ**

ឈ្មោះ [redacted] រក្សា ភេទស្រី កើតឆ្នាំ១៩៨៤ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន [redacted]។

អ្នកតំណាងដោយអាណត្តិៈ មេធាវី [redacted]។

**សហចុងចម្លើយៈ**

១. ឈ្មោះ [redacted] សុខ ភេទប្រុស កើតឆ្នាំ១៩៥៨ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះ [redacted]។

២. ឈ្មោះ [redacted] ហេង ភេទស្រី កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះ [redacted]។

អ្នកតំណាងដោយអាណត្តិៈ មេធាវី [redacted]។

**អង្គហេតុ និងការអះអាងរបស់គូភាគី**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖**

១.ស្នើសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារលេខៈ០១១ ដ.រ.ប/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល លើដីដែលមានទំហំ៣០,៧២៧ (បីម៉ឺនប្រាំពីររយម្ភៃប្រាំពីរ) ម៉ែត្រការ៉េ ទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ១២៩៨/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ចេញដោយរដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

**ខ. ការសង្ខេបគ្រួសៗអំពីអង្គហេតុ**

កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ សាលាដំបូងខេត្តកណ្តាល បានចេញដីកាសម្រេចចាត់ចែងរក្សាការពារលេខៈ០១១ ដ.រ.ប/២៣ ដោយហាមឃាត់កូនបំណុលឈ្មោះ [redacted] លំអ មិនឱ្យធ្វើការចាត់ចែង និងផ្ទេរកាន់កាប់ ( លក់ដូរ ជួលបញ្ចាំ ផ្ទេរសិទ្ធិ ដាក់ហ៊ីប៉ូតែក ធ្វើប្រទានកម្ម ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើមរតក

Scanned with CamScanner

ជាអាទិ៍) និងធ្វើសកម្មភាពផ្សេងៗ (ឈូសឆាយ ដីកដីចាក់ សាងសង់សំណង់ ជាអាទិ៍) ចំពោះអចលនវត្ថុដែលជាដីចំនួន ០១ (មួយ) កន្លែងមានទំហំ២០,០១៣ (ពីរម៉ឺនដប់បី) ម៉ែត្រការ៉េ ទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលមិនទាន់ចុះបញ្ជីលេខ ៣២០៥/១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ចេញដោយរដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល។ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ក្រលាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល បានចេញលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុលេខៈ៤៩៩ ដ.រ.ប/២៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ហើយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដើមចោទបានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនមកសាលាដំបូងខេត្តកណ្តាល។

ខ.ក.១ រឿងក្តីនេះលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted]រក្សា ធ្វើសេចក្តីថ្លែងការណ៍ថា៖ *កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ សាលាដំបូងខេត្តកណ្តាល បានចេញដីកាសម្រេចចាត់ចែងរក្សាការពារលេខៈ០១១ ដ.រ.ប/២៣ ដោយហាមឃាត់កូនបំណុលឈ្មោះ [redacted] លំអ មិនឱ្យធ្វើការចាត់ចែង និងផ្ទេរការកាន់កាប់ លក់ដូរ ជួលបញ្ចាំ ផ្ទេរសិទ្ធិ ដាក់ហ៊ីប៉ូតែក ធ្វើប្រទានកម្ម ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើមរតក ជាអាទិ៍ និងធ្វើសកម្មភាពផ្សេងៗ ឈូសឆាយ ដីកដីចាក់ សាងសង់សំណង់ ជាអាទិ៍ ចំពោះអចលនវត្ថុដែលជាដីចំនួន០១ កន្លែងមានទំហំ ២០,០១៣ (ពីរម៉ឺនដប់បី) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ៣២០៥/១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ចេញដោយរដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល។ លុះដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ សាលាដំបូងខេត្តកណ្តាល បានចេញលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុលេខៈ៤៩៩ រ.ប/២៣ចុះថ្ងៃ ទី១៦ ខែមិថុនា ឆ្នាំ២០២៣ យោងតាមសេចក្តីសម្រេចចំណុច "ក" នៃដីកាសម្រេចចាត់ចែងរក្សាការពារលេខៈ០១១ ដ.រ.ប/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ សាលាដំបូងខេត្តកណ្តាល បានផ្ទុកផ្តាក់លើកម្មសិទ្ធិរបស់កូនក្តីយើងខ្ញុំឈ្មោះ រស់ រក្សា មានទំហំសរុប៣០,៧២៧ (បីម៉ឺនប្រាំពីររយម្ភៃប្រាំពីរ) ម៉ែត្រការ៉េ ទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ទៅវិញ។ ការសម្រេចខាងលើនេះ ពិតជាធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិដែលជាផលប្រយោជន៍ស្របច្បាប់របស់កូនក្តីយើងខ្ញុំយ៉ាងធ្ងន់ធ្ងរបំផុត ដោយហេតុថា កូនក្តីយើងខ្ញុំជាកម្មសិទ្ធិករ ដូចមានបញ្ជាក់ក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ១២៩៨/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ហើយកូនក្តីយើងខ្ញុំក៏បានបង់ពន្ធប្រថាប់ត្រារួចរាល់ផងដែរ។ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅសាលាដំបូងខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ សាលាដំបូងខេត្តកណ្តាល បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើសំណុំរឿងរដ្ឋប្បវេណីលេខៈ៧២៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល បន្ទាប់ពីមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានថ្លែងការណ៍តបរួចរាល់ តុលាការបានកំណត់ចំណុចវិវាទថា៖ "តើការតវ៉ារបស់តតិយជនជាអ្នកដាក់ពាក្យសុំតវ៉ា មានមូលហេតុត្រឹមត្រូវតាមផ្លូវច្បាប់ដែរឬទេ?" ហើយបានកំណត់កាលបរិច្ឆេទសម្រាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង៣ រសៀល។ មូលដ្ឋានក្នុងការសុំលុបចោលការអនុវត្តដីកាសម្រេចរក្សាការពារលេខៈ០១១ ដ.រ.ប/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល ដោយសារមានកូនបំណុលនៃរក្សាការពារឈ្មោះ [redacted] លំអ តែបែរជាអនុវត្តលើដីកម្មសិទ្ធិរបស់កូនក្តីយើងខ្ញុំទៅវិញ។ យោងតាមលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុលេខៈ៤៩៩ រ.ប/២៣ ចុះថ្ងៃ ទី១៦ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល ការសុំអនុវត្តរក្សាការពារលើអចលនទ្រព្យរបស់កូនបំណុលឈ្មោះ [redacted] លំអ លើដីទំហំ២០,០១៣ (ពីរម៉ឺនដប់បី) ម៉ែត្រការ៉េ មាន*

Scanned with CamScanner

ទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ៣២០៥/១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ចេញដោយរដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល តែតុលាការអនុវត្តបែរជាការអនុវត្តលើដីរបស់កូនក្តីយើងខ្ញុំឈ្មោះ [redacted] រក្សា ទៅវិញ។ កូនក្តីយើងខ្ញុំជាកម្មសិទ្ធិករលើដីទំហំ៣០,៧២៧ (បីម៉ឺនប្រាំពីររយម្ភៃប្រាំពីរ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ហើយដីនោះមិនមែនឈ្មោះ [redacted] លំអ នោះទេ។ ការស្នើសុំអនុវត្តដីកាសម្រេចរក្សាការពាររបស់ឈ្មោះ [redacted] សុង និងឈ្មោះ [redacted] ហេង គឺធ្វើក្រោយពេលដែលឈ្មោះ [redacted] លំអ ផ្ទេរកម្មសិទ្ធិមកកូនក្តីយើងខ្ញុំ ហើយក្នុងអំឡុងពេលដែលកូនក្តីយើងខ្ញុំផ្ទេរកម្មសិទ្ធិនោះគឺពុំមានការតវ៉ាតាំង ឬមានការហាមឃាត់ពីភាគីណាឡើយ។ ហេតុនេះ ការអនុវត្តនេះ ជាការអនុវត្តលើដីរបស់កូនក្តីយើងខ្ញុំ ដោយមិនមែនជាកាអនុវត្តស្របតាមកម្មវត្ថុនៃការអនុវត្តដីកាសម្រេចរក្សាការពារ ដែលជាទ្រព្យសម្បត្តិរបស់កូនបំណុលឈ្មោះ [redacted] លំអ នោះទេ។ អំពីទាក់ទងនឹងច្បាប់យោងតាមអង្គហេតុដូចបានរៀបរាប់ខាងលើ យើងខ្ញុំសូមលើកអង្គច្បាប់តាមបញ្ញត្តិមាត្រា១៣៣ ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង នៃក្រមរដ្ឋប្បវេណី "ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាពតាមការព្រមព្រៀងរវាងគូភាគី"។ មាត្រា៣៦៥ បណ្តឹងតវ៉ារបស់តតិយជន នៃក្រមនីតិវិធីរដ្ឋប្បវេណី "តតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំ ចំពោះម្ចាស់បំណុលនៃការ អនុវត្តនោះបាន។... "។

ហេតុដូច្នេះ យើងខ្ញុំជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] រក្សា សូមស្នើសុំឱ្យតុលាការមេត្តាសម្រេចលុបចោលការអនុវត្តដីកាសម្រេចរក្សាការពារលេខៈ០១១ ដ.រ.ប/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល លើដីមានទំហំ៣០,៧២៧ (បីម៉ឺនប្រាំពីររយម្ភៃប្រាំពីរ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ១២៩៨/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ចេញដោយរដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល។

ខ.ក.២. រឿងក្តីនេះចុងចម្លើយលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិសហចុងចម្លើយឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង ធ្វើសេចក្តីថ្លែងការណ៍តបថា៖ ចំពោះដីទំហំ២០០១៣ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ហៃ។ បន្ទាប់មកនៅឆ្នាំ២០១៩ ឈ្មោះ [redacted] ហៃ បានយកដីដែលជាកម្មសិទ្ធិរបស់ខ្លួនខាងលើនេះមួយផ្នែកទំហំ២០,០១៣ ម៉ែត្រការ៉េ លក់មកឲ្យឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង ដោយមានការដឹងលឺជាសាធារណៈ អត់មានជំទាស់ពីបុគ្គលណាមួយឡើយ ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩, លិខិតបញ្ជាក់អំពីការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ និងបង្កាន់ដៃបញ្ជាក់អំពីការបង់ពន្ធ លិខិតកំណត់ហេតុស្តីពីការចុះវាស់វែងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ ពាក្យស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី១៩ខែ សីហា ឆ្នាំ២០១៩ លិខិតជូនដំណឹងស្តីពីការចុះវាស់វែងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ៤៣២៧/១៩ ចុះថ្ងៃទី២៩ខែសីហា ឆ្នាំ២០១៩ សលាបត្រវាស់វែងលេខៈ១៥៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ និងកិច្ចសន្យាលក់-ទិញដី រវាងឈ្មោះ [redacted] ហៃ ជាមួយនឹងឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង ដែលបានទូទាត់ប្រាក់ថ្លៃទិញដីគ្រប់ចំនួនត្រឹមត្រូវតាមច្បាប់ រួចបានគ្រប់គ្រងដីខាងលើក្នុងនាមជាម្ចាស់កម្មសិទ្ធិករ។ នៅពេលនេះទើបឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង បានដឹងថាដីរបស់ខនដែលបានទិញពីឈ្មោះ [redacted] ហៃ កាលពីឆ្នាំ២០១៩ ដោយមានការដឹងឮជាសាធារណៈ មាន

Scanned with
CamScanner

*ការទទួលស្គាល់ពីអាជ្ញាធរដែនដីខាងលើ ត្រូវបានតុលាការសម្រេចឱ្យឈ្មោះ ហិល ហៃ ផ្ទេរឱ្យទៅឈ្មោះ [redacted] លំអ វិញ។ ក្រោយមកឈ្មោះ [redacted] លំអ បានយកសេចក្តីសម្រេចរបស់តុលាការនោះទៅធ្វើការអនុវត្តផ្ទេរសិទ្ធិត្រឡប់មកវិញពីឈ្មោះ [redacted] ហៃ ឱ្យមកខ្លួនវិញ ដូចមានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ មានការទទួលស្គាល់ពីរដ្ឋបាលស្រុកពញាឮ។ ពាក់ព័ន្ធនឹងករណីវិវាទនៅតុលាការរវាងឈ្មោះ [redacted] លំអ ជាមួយនឹងឈ្មោះ [redacted] ហៃ នេះ គឺឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង ពុំបានដឹងទេ។ ក្រោយពីឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង បានទទួលដំណឹងថាដីដែលបានទិញស្របច្បាប់ ដោយសុចរិត មានការដឹងឮពីអាជ្ញាធរដែនដីពីឈ្មោះ [redacted] ហៃ ត្រូវបានផ្ទេរឱ្យទៅឈ្មោះ [redacted] លំអ វិញ ទើបឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង ដាក់ស្នើសុំដីការសម្រេចរក្សាការពារពីតុលាការ ដើម្បីធ្វើការហាមឃាត់កុំឱ្យមានការចាត់ចែង ធ្វើសកម្មភាពណាមួយដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង។ ក្រៅពីនេះ បន្ទាប់បានដឹងអំពីការអនុវត្តសាលក្រមរដ្ឋប្បវេណីលេខៈ០២៤ ស.រ.ណ/២១ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាល ឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ដើម្បីទាមទារឱ្យតុលាការលុបចោលការអនុវត្តដោយបង្ខំនោះវិញផងដែរ។ ចំពោះពាក្យបណ្តឹងតវ៉ារបស់តតិយជនឈ្មោះ [redacted] រក្សា បានលើកឡើងថា មិនមានទំនាក់ទំនងតតិយុត្តជាមួយនឹងឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] លំអ នោះជារឿងមិនត្រឹមត្រូវទេ ពីព្រោះថា ដីដែលជាកម្មវត្ថុនៃការអនុវត្តរក្សាការពារនោះ គឺឈ្មោះ [redacted] លំអ បានលក់ឱ្យទៅឈ្មោះ [redacted] រក្សា ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ គឺមានទំនាក់ទំនងតតិយុត្តនឹងគ្នា ហើយផ្អែកតាមអង្គហេតុខាងលើនេះ បញ្ជាក់ឱ្យឃើញថា ការអនុវត្តរក្សាការពាររបស់ឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង ត្រូវតែធ្វើជាចាំបាច់ ដើម្បីកុំឱ្យមានការលំបាកក្នុងអនុវត្តសេចក្តីសម្រេចស្ថាពរនាពេលខាងមុខ ហើយត្រូវរង់ចាំការដោះស្រាយក្នុងរឿងអង្គសេចក្តីចប់ជាស្ថាពរសិន។ យើងខ្ញុំជាមេធាវីតំណាងអាណត្តិឲ្យចុងចម្លើយ សំណូមពរឱ្យតុលាការលើកចោលពាក្យបណ្តឹងតវ៉ារបស់តតិយជន ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] រក្សា ចោល ហើយបន្តនីតិវិធីផ្អុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នលេខលិខិតផ្អុកផ្តាក់លេខៈ៤៩៩ រ.ឋ/២៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល។*

**ខ.ខ អង្គហេតុដែលគ្មានវិវាទ**

កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ សាលាដំបូងខេត្តកណ្តាល បានចេញដីកាសម្រេចចាត់ចែងរក្សាការពារលេខៈ០១១ ដ.រ.ឋ/២៣ ដោយហាមឃាត់កូនបំណុលឈ្មោះ [redacted] លំអ មិនឱ្យធ្វើការចាត់ចែង និងផ្ទេរកាន់កាប់ (លក់ដូរ ជួលបញ្ចាំ ផ្ទេរសិទ្ធិ ដាក់ហ៊ីប៉ូតែក ធ្វើប្រទានកម្ម ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើមរតក ជាអាទិ៍) និងធ្វើសកម្មភាពផ្សេងៗ (ឈូសឆាយ ដឹកដីចាក់ សាងសង់សំណង់ ជាអាទិ៍) ចំពោះអចលនវត្ថុដែលជាដីចំនួន០១ (មួយ) កន្លែង មានទំហំ ២០,០១៣ (ពីរម៉ឺនដប់បី) ម៉ែត្រការ៉េ ទីតាំងស្ថិតនៅភូមិត្រពាំងឫស្សី ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល មានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ៣២០៥/១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ចេញដោយរដ្ឋបាលស្រុកពញាឮ ខេត្តកណ្តាល និងនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល បានចេញលិខិតផ្អុកផ្តាក់ឲ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុលេខៈ៤៩៩ ដ.រ.ឋ/២៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។

**ខ.គ ចំណុចវិវាទ**

១.តើការប្តឹងតវ៉ារបស់តតិយជនរបស់អ្នកដាក់ពាក្យសុំតវ៉ា មានមូលហេតុត្រឹមត្រូវតាមផ្លូវច្បាប់ដែរឬទេ ?

**គ. ការពិនិត្យភស្តុតាង**

-ឯកសារថតចម្លង លិខិតបញ្ជាក់អំពីតម្លៃដីអចលនវត្ថុ(ដី) ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣។

Scanned with CamScanner

-ឯកសារថតចម្លង ដីកាសម្រេចចាត់ចែងរក្សាការពារលេខៈ០១១ ដ.រ.ប.២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុលេខៈ ៤៩៩ រ.ប/២៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជីលេខៈ១២០៩/២៣ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជីលេខៈ១២៩៨/២៣ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង លិខិតបញ្ជាក់អំពីការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យលេខៈ៣០៨៩៧ អពដ.នចអ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធលេខៈ008879658 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២៣។

-ឯកសារថតចម្លង ដីកាបញ្ជូនលេខៈ១៤៣៦/២០២៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង ពាក្យស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ១៣២៦/ ២០២៣ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង លិខិតធានាអះអាងលេខៈ១៣២៦/២០២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង កិច្ចសន្យាលេខៈ១៣២៦/២០២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង លិខិតជូនដំណឹងស្តីពីការចុះវាស់វែងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ ៧០២/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង កំណត់ហេតុស្តីពីការចុះត្រួតពិនិត្យវាស់វែងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង សលាកបត្រសម្រង់ជាក់ស្តែងនៃអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ១៤៤ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។

-ឯកសារថតចម្លង អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ011182472 ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] លំអ។

-ឯកសារថតចម្លង អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ010541929(01) ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted] រក្សា។

-ឯកសារថតចម្លង កិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩។

-ឯកសារថតចម្លង លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ៣២០៥/១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩។

-ឯកសារថតចម្លង ពាក្យស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ១៣៩២/២០១៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។

-ឯកសារថតចម្លង លិខិតជូនដំណឹងស្តីពីការចុះវាស់វែងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខៈ៤៣២៧/ ១៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។

-ឯកសារថតចម្លង កំណត់ហេតុស្តីពីការចុះវាស់វែងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩។

-ឯកសារថតចម្លង សលាកបត្រវាស់វែងលេខៈ១៥៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។

Scanned with CamScanner

## សំអាងហេតុ

១. បណ្ដឹងតវ៉ារបស់តតិយជនដែលធ្វើឡើងដោយដើមចោទ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ដែលអាចឲ្យតុលាការលើកយកមកពិចារណាបាន។

២. តាមការពិនិត្យទៅលើការអះអាងរបស់ភាគី និងតាមការពិនិត្យទៅលើកស្តុតាងជាឯកសារដែលមាននៅក្នុងសំណុំរឿងតុលាការពិនិត្យឃើញថា កាលបរិច្ឆេទនៃការផ្ទុកផ្ដាក់ដីកាសម្រេចរក្សាការពារលេខៈ ០១១ដ.រ.ឋ/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្ដាល តាមរយៈលិខិតផ្ទុកផ្ដាក់លេខៈ៤៩៩រ.ឋ/២៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល គឺធ្វើឡើងក្រោយការផ្ទេរសិទ្ធិរវាងកូនបំណុលនៃរក្សាការពារមកឲ្យដើមចោទឈ្មោះ [redacted] រក្សា តាមរយៈលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជីលេខៈ១២៩៨/២៣ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ដែលឃើញថា នាំឲ្យដីកាសម្រេចរក្សាការពារខាងលើត្រូវបានអនុវត្តចំពោះសិទ្ធិរបស់តតិយជនឈ្មោះ [redacted] រក្សា ដែលពុំមានទំនាក់ទំនងគតិយុត្តិជាមួយនឹងចុងចម្លើយ ដែលជាម្ចាស់បំណុលនៃដីកាសម្រេចរក្សាការពារខាងលើនោះឡើយ ហេតុនេះគប្បីតុលាការសម្រេចលុបចោលដីកាសម្រេចរក្សាការពារលេខៈ០១១ដ.រ.ឋ/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣ និងការចុះបញ្ជីផ្ទុកផ្ដាក់ដីកាសម្រេចរក្សាការពារខាងលើនេះចោល។

៣. ផ្អែកតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី ។

## សេចក្ដីសម្រេចបញ្ចប់

១.លុបចោលដីកាសម្រេចចាត់ចែងរក្សាការពារលេខៈ០១១ ដ.រ.ឋ/២៣ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ២០២៣ និងលិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុលេខៈ៤៩៩ រ.ឋ/ ២៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្ដាល។

២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផល ប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខដើមចោទឈ្មោះ [redacted] រក្សា និងសហចុងចម្លើយឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ហេង។

*ភាគីដែលមិនសុខចិត្តមានសិទ្ធិប្ដឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមការកំណត់របស់ច្បាប់។*

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

-បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម-

ថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្ដាល, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner